# សន្ធិសញ្ញាទីក្រុងប៉េកាំងស្ដីពីការសម្ដែងសោតទស្សន៍*

## មាតិកា


**បុព្វកថា**

មាត្រា១: ទំនាក់ទំនងជាមួយអនុសញ្ញានិងសន្ធិសញ្ញាផ្សេងទៀត

មាត្រា២: និយមន័យ

មាត្រា៣: អ្នកទទួលផលពីកិច្ចការពារ

មាត្រា៤: ប្រព្រឹត្តកម្មជាតិ

មាត្រា៥: សិទ្ធិសីលធម៌

មាត្រា៦: សិទ្ធិបេតិកភណ្ឌរបស់អ្នកសម្ដែងចំពោះការសម្ដែងដែលមិនបានថតបញ្ចូល

មាត្រា៧: សិទ្ធិផលិតឡើងវិញ

មាត្រា៨: សិទ្ធិចែកចាយ

មាត្រា៩: សិទ្ធិជួល

មាត្រា១០: សិទ្ធិដាក់ផ្សាយការសម្ដែងដែលបានថតបញ្ចូល

មាត្រា១១: សិទ្ធិផ្សាយតាមទូរផ្សាយនិងផ្សព្វផ្សាយជាសាធារណៈ

មាត្រា១២: ការផ្ទេរសិទ្ធិ

មាត្រា១៣: ការកម្រិតនិងការលើកលែង

មាត្រា១៤: រយៈពេលនៃកិច្ចការពារ

មាត្រា១៥: កាតព្វកិច្ចចំពោះវិធានការបច្ចេកវិជ្ជា

មាត្រា១៦: កាតព្វកិច្ចចំពោះសិទ្ធិគ្រប់គ្រងព័ត៌មាន

មាត្រា១៧: លក្ខខណ្ឌទម្រង់

មាត្រា១៨: ខរក្សាសិទ្ធិ និងសេចក្ដីជូនដំណឹង

មាត្រា១៩: ការអនុវត្តក្នុងពេលវេលា

មាត្រា២០: បទប្បញ្ញត្តិចំពោះការអនុវត្តសិទ្ធិ

មាត្រា២១: សន្និបាត

មាត្រា២២: ការិយាល័យអន្តរជាតិ

មាត្រា២៣: លក្ខខណ្ឌដើម្បីក្លាយជាភាគីនៃសន្ធិសញ្ញា


---

* សន្ធិសញ្ញានេះត្រូវបានអនុម័តដោយសន្និសីទការទូតស្ដីពីកិច្ចការពារការសម្ដែងសោតទស្សន៍នៅទីក្រុងប៉េកាំងចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២

មាត្រា២៤:	សិទ្ធិនិងកាតព្វកិច្ចតាមសន្ធិសញ្ញា
មាត្រា២៥:	ការចុះហត្ថលេខាលើសន្ធិសញ្ញា
មាត្រា២៦:	ការចូលជាធរមាននៃសន្ធិសញ្ញា
មាត្រា២៧:	កាលបរិច្ឆេទសុពលភាពដើម្បីក្លាយជាភាគីនៃសន្ធិសញ្ញា
មាត្រា២៨:	ការប្រកាសដកខ្លួនចេញពីសន្ធិសញ្ញា
មាត្រា២៩:	ភាសាក្នុងសន្ធិសញ្ញា
មាត្រា៣០:	កន្លែងតម្កល់

## បុព្វកថា

ភាគីហត្ថលេខីទាំងឡាយ

ដោយចេតនា ដើម្បីអភិវឌ្ឍនិងរក្សាកិច្ចការពារសិទ្ធិអ្នកសម្តែងចំពោះការសម្តែងសោតទស្សន៍របស់ខ្លួន ប្រកបដោយប្រសិទ្ធិភាពនិងឯកសណ្ឋានភាពតាមដែលអាចធ្វើទៅបាន។

ដោយយល់ឃើញអំពីសារៈសំខាន់នៃអនុសាសន៍ចំពោះកម្មវិធីអភិវឌ្ឍ ដែលបានអនុម័តក្នុងឆ្នាំ២០០៧ ដោយមហាសន្និបាតនៃអនុសញ្ញាស្តីពីការបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលមានគោលដៅដើម្បីធានាថាការពិចារណាដើម្បីអភិវឌ្ឍជាផ្នែកនៃកិច្ចការទាំងមូលរបស់អង្គការ។

ដោយទទួលស្គាល់ នូវតម្រូវការក្នុងការបញ្ចូលវិធានអន្តរជាតិថ្មីៗដើម្បីផ្តល់ដំណោះស្រាយសមរម្យចំពោះបញ្ហាដែលកើតឡើងពីការអភិវឌ្ឍន៍ទាក់ទងនឹង សេដ្ឋកិច្ច សង្គម វប្បធម៌ និង បច្ចេកវិជ្ជា។

ដោយទទួលស្គាល់ នូវឥទ្ធិពលខ្លាំងក្លានៃការអភិវឌ្ឍន៍និងដើម្បីឱ្យមានគោលដៅតែមួយ ចំពោះព័ត៌មាននិងទំនាក់ទំនងបច្ចេកវិជ្ជាចំពោះការផលិតនិងការប្រើប្រាស់ ការសម្តែងសោតទស្សន៍។

ដោយទទួលស្គាល់ នូវតម្រូវការដើម្បីរក្សាឱ្យមានតុល្យភាពរវាងសិទ្ធិអ្នកសម្តែងចំពោះការសម្តែងសោតទស្សន៍របស់ខ្លួន និងផលប្រយោជន៍សាធារណៈជនភាគច្រើន ជាពិសេសចំពោះការអប់រំ ការស្រាវជ្រាវ និងសិទ្ធិទទួលបានព័ត៌មាន។

ដោយទទួលស្គាល់ថា សន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែងនិងហ្វូណូក្រាមដែលបានធ្វើនៅទីក្រុងហ្សឺណែវ ចុះថ្ងៃទី២០ខែធ្នូឆ្នាំ១៩៩៦មិនបានពង្រីកកិច្ចការពារដល់អ្នកសម្តែង ចំពោះការសម្តែងដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍របស់ខ្លួន។

ដោយយោងតាម ដំណោះស្រាយទាក់ទងនឹងការសម្តែងសោតទស្សន៍ដែលបានអនុម័តដោយសន្និសីទការទូត ស្តីពីបញ្ហាសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលមួយចំនួនចុះថ្ងៃទី២០ខែធ្នូ ឆ្នាំ១៩៩៦

បានយល់ព្រមដូចខាងក្រោមៈ

## មាត្រា១

## ទំនាក់ទំនងជាមួយអនុសញ្ញានិងសន្ធិសញ្ញាផ្សេងទៀត

(១) សន្ធិសញ្ញានេះមិនត្រូវថែងផ្ទុយពីកាតព្វកិច្ចដែលមានស្រាប់ ដែលភាគីហត្ថលេខីទាំងឡាយមានចំពោះគ្នាទៅវិញទៅមក តាមសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែងនិងហ្វូណូក្រាម ឬអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារអ្នកសម្តែង ផលិតករហ្វូណូក្រាមនិងអង្គភាពទូរផ្សាយ ដែលបានធ្វើនៅទីក្រុងរ៉ូមចុះថ្ងៃទី២៦ ខែតុលាឆ្នាំ១៩៦១។

(២) កិច្ចការពារដែលផ្តល់ឱ្យតាមសន្ធិសញ្ញានេះ ត្រូវរក្សាដដែលនិងមិនត្រូវធ្វើឱ្យប៉ះពាល់ដល់កិច្ចការពារសិទ្ធិអ្នកនិពន្ធនៃស្នាដៃអក្សរសាស្ត្រនិងសិល្បៈឡើយ។ ដូច្នេះបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះមិនអាចត្រូវបកស្រាយ ដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចការពារនេះទេ។

(៣) សន្ធិសញ្ញានេះមិនត្រូវមានទំនាក់ទំនងជាមួយសន្ធិសញ្ញាណាមួយផ្សេងពីសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែងនិងហ្វូណូក្រាម ឬក៏មិនត្រូវប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចដែលមានក្នុងសន្ធិសញ្ញាផ្សេងទៀតឡើយ[១,២]។

## មាត្រា២

## និយមន័យ

ក្នុងគោលបំណងនៃសន្ធិសញ្ញានេះៈ

---

[១] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា១: ត្រូវយល់ថាសន្ធិសញ្ញានេះមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចណាមួយតាមសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែងនិងហ្វូណូក្រាម(WPPT) ឬការបកស្រាយរបស់សន្ធិសញ្ញានេះ ហើយត្រូវយល់បន្តទៀតថាកថាខណ្ឌ(៣)មិនបង្កើតឱ្យមានកាតព្វកិច្ចណាមួយចំពោះភាគីហត្ថលេខីនៃសន្ធិសញ្ញានេះដើម្បីផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីការសម្តែងនិងហ្វូណូក្រាម ឬអនុលោមតាមបទប្បញ្ញត្តិណាមួយនៃសន្ធិសញ្ញានេះ។

[២] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា១(៣): ត្រូវយល់ថាភាគីហត្ថលេខីដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) ទទួលស្គាល់នូវគោលការណ៍និងគោលដៅទាំងអស់នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ហើយយល់ថាសន្ធិសញ្ញានេះមិនធ្វើឱ្យប៉ះពាល់ដល់បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា(កិច្ចព្រមព្រៀងTRIPS) និងយល់ថាសន្ធិសញ្ញានេះមិនធ្វើឱ្យប៉ះពាល់ដល់បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងTRIPSដោយរាប់បញ្ចូល ប៉ុន្តែមិនកម្រិតចំពោះបទប្បញ្ញត្តិទាំងឡាយទាក់ទងនឹងការអនុវត្តផ្ទុយនឹងការប្រកួតប្រជែង។

(ក) " អ្នកសម្តែង" ជាសិល្បៈករ អ្នកចម្រៀង តន្ត្រីករ អ្នករបាំ និងបុគ្គលផ្សេងទៀតដែល ដើរតួ ច្រៀង សូត្រ ថ្លែងជំទាស់ សម្តែងតួ បកស្រាយ ឬសម្តែងស្នាដៃអក្សរសាស្ត្រឬ សិល្បៈផ្សេងទៀត ឬសម្តែងការបង្ហាញរបាំប្រពៃណី[៣]។

(ខ) "ការថតបញ្ចូលសោតទស្សន៍" មានន័យថាជាការបញ្ចូលរូបភាពមានចលនា ទោះ បីមានឬគ្មានសម្លេងឬនិមិត្តសញ្ញានៃសម្លេងក៏ដោយ ដែលអាចត្រូវបានទទួល ត្រូវផលិត ឡើងវិញឬត្រូវផ្សព្វផ្សាយតាមរយៈឧបករណ៍ណាមួយ[៤]

(គ) "ទូរផ្សាយ" ជាការផ្សាយតាមមធ្យោបាយឥតខ្សែដើម្បីឱ្យសាធារណៈជនទទួលបាន នូវសម្លេង ឬរូបភាព ឬរូបភាពនិងសម្លេង ឬនិមិត្តសញ្ញានៃសម្លេងឬរូបភាព។ ការផ្សាយ តាមផ្កាយរណបក៏ជា"ទូរផ្សាយ"ផងដែរ ការផ្សាយតាមសញ្ញាលេខកូដជា"ទូរផ្សាយ"នៅ ពេលដែលមធ្យោបាយនៃការដោះលេខកូដ ត្រូវបានផ្តល់ឱ្យសាធារណៈជនដោយអង្គភាព ទូរផ្សាយ ឬដោយមានការយល់ព្រមពីអង្គភាពនេះ។

(ឃ) "ការផ្សព្វផ្សាយជាសាធារណៈ"នៃការសម្តែងមានន័យថា ជាការផ្សាយទៅសាធារណៈជនតាមមធ្យោបាយផ្សព្វផ្សាយណាមួយនៃការសម្តែងដែលមិនបានថតបញ្ចូល ឬការ សម្តែងដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍ ក្រៅពីការផ្សាយតាមទូរផ្សាយ។ ក្នុងបំណងនៃមាត្រា១១"ការផ្សព្វផ្សាយជាសាធារណៈ" ត្រូវរាប់បញ្ចូលទាំងការ បង្កើតការសម្តែងដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍ ដែលអាចធ្វើឱ្យ សាធារណៈស្តាប់ឮបាន ឬមើលឃើញបាន ឬស្តាប់ឮនិងមើលឃើញបាន។

## មាត្រា៣

## អ្នកទទួលផលពីកិច្ចការពារ

(១) ភាគីហត្ថលេខី ត្រូវផ្តល់កិច្ចការពារដែលមានចែងតាមសន្ធិសញ្ញានេះ ចំពោះអ្នកសម្តែង ដែលជាពលរដ្ឋនៃភាគីហត្ថលេខីផ្សេងទៀត។

(២) ក្នុងបំណងនៃសន្ធិសញ្ញានេះ អ្នកសម្តែងដែលមិនមែនជាពលរដ្ឋនៃភាគីហត្ថលេខី ប៉ុន្តែមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសមួយដែលជាភាគីហត្ថលេខី ត្រូវចាត់ទុកដូច ជាពលរដ្ឋនៃភាគីហត្ថលេខីដែរ។

---

[៣] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា២(ក): ត្រូវយល់ថានិយមន័យពាក្យ"អ្នកសម្តែង" រួមបញ្ចូលទាំងជនដែលធ្វើការសម្តែងស្នាដៃអក្សរសាស្ត្រនិងសិល្បៈដែលបានបង្កើតឡើងឬ ថតបញ្ចូលលើកដំបូងក្នុងពេលសម្តែង។

[៤] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា២(ខ): តាមន័យនេះបញ្ជាក់ថានិយមន័យពាក្យ "ការថតបញ្ចូលសោតទស្សន៍" ដែលមានក្នុងមាត្រា២(ខ)មិនធ្វើឱ្យប៉ះពាល់ដល់មាត្រា២(គ)នៃសន្ធិសញ្ញាWPPTឡើយ។

## មាត្រា៤
## ប្រព្រឹត្តកម្មជាតិ

(១) ភាគីហត្ថលេខីនីមួយៗត្រូវផ្តល់ឱ្យពលរដ្ឋនៃភាគីហត្ថលេខីផ្សេងទៀត នូវប្រព្រឹត្តកម្មដែលភាគីហត្ថលេខីបានផ្តល់ចំពោះ ពលរដ្ឋរបស់ខ្លួនទាក់ទងនឹងសិទ្ធិផ្តាច់មុខ ដែលបានផ្តល់ឱ្យជាក់លាក់តាមសន្ធិសញ្ញានេះ និងចំពោះសិទ្ធិទទួលបានលាភការសមរម្យដែលមានចែងតាមមាត្រា១១នៃសន្ធិសញ្ញានេះ។

(២) ភាគីហត្ថលេខីមួយមានសិទ្ធិកម្រិតវិសាលភាពនិងរយៈពេលនៃកិច្ចការពារ ដែលផ្តល់ឱ្យពលរដ្ឋនៃភាគីហត្ថលេខីផ្សេងទៀតតាមកថាខណ្ឌ(១) ចំពោះសិទ្ធិដែលបានផ្តល់ឱ្យតាមមាត្រា១១(១)និងមាត្រា១១(២)នៃសន្ធិសញ្ញានេះ ទាក់ទងនឹងសិទ្ធិទាំងឡាយដែលពលរដ្ឋរបស់ខ្លួនទទួលបានក្នុងភាគីហត្ថលេខីផ្សេងទៀត ។

(៣) កាតព្វកិច្ចដែលមានចែងក្នុងកថាខណ្ឌ(១) មិនអនុវត្តចំពោះភាគីហត្ថលេខីមួយនៅពេលដែលភាគីហត្ថលេខីមួយផ្សេងទៀតបានប្រើប្រាស់ខរក្សាសិទ្ធិ ដែលមាត្រា១១(៣) នៃសន្ធិសញ្ញានេះបានអនុញ្ញាត ហើយក៏មិនអនុវត្តចំពោះភាគីហត្ថលេខីណាមួយដែលបានធ្វើខរក្សាសិទ្ធិនេះ។

## មាត្រា៥
## សិទ្ធិសីលធម៌

(១) ដោយឯករាជ្យពីសិទ្ធិបេតិកភណ្ឌរបស់អ្នកសម្តែង និងទោះបីបន្ទាប់ពីការផ្ទេរសិទ្ធិទាំងនេះក៏ដោយ ចំពោះការសម្តែងផ្ទាល់ឬការសម្តែងដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍ អ្នកសម្តែងត្រូវមានសិទ្ធិៈ

(i) ទាមទារឱ្យមានការទទួលស្គាល់ឈ្មោះជា អ្នកសម្តែងចំពោះការសម្តែងរបស់ខ្លួនលើកលែងតែវិធីប្រើប្រាស់នៃការសម្តែងនោះមិនតម្រូវឱ្យដាក់ឈ្មោះ និង

(ii) ជំទាស់នូវរាល់ការបំផ្លើស ការកាត់តខ្លឹមសារ ឬការកែប្រែខ្លឹមសារ នៃការសម្តែងជាហេតុធ្វើឱ្យខូចកេរ្តិ៍ឈ្មោះអ្នកសម្តែង ដោយគិតទៅលើលក្ខណៈនៃការថតបញ្ចូលសោតទស្សន៍។

(២) សិទ្ធិដែលបានផ្តល់ឱ្យអ្នកសម្តែងតាមកថាខណ្ឌ(១) បន្ទាប់ពីមរណៈភាពរបស់អ្នកសម្តែងត្រូវរក្សាទុកយ៉ាងហោចណាស់ត្រឹមពេលផុតកំណត់សិទ្ធិបេតិកភណ្ឌ ហើយសិទ្ធិនេះនឹងត្រូវបានអនុវត្តដោយ បុគ្គលឬស្ថាប័នដែលបានអនុញ្ញាតដោយច្បាប់របស់ភាគីហត្ថលេខីដែលត្រូវបានអះអាងឱ្យការពារ។ ប៉ុន្តែនៅពេលផ្តល់សច្ចាប័នឬចូលជាសមាជិកនៃសន្ធិសញ្ញានេះ ភាគីហត្ថលេខីដែលច្បាប់របស់ខ្លួបមិនចែងអំពីកិច្ចការពារសិទ្ធិទាំង

ឡាយបន្ទាប់ពីមរណៈភាពរបស់អ្នកសម្តែង តាមកថាខណ្ឌខាងលើអាចចែងថាសិទ្ធិមួយចំនួន លែងត្រូវរក្សាទុកបន្ទាប់ពីមរណៈភាពរបស់អ្នកសម្តែង។

(៣) មធ្យោបាយជួសជុលការខូចខាតដើម្បីរក្សាសិទ្ធិតាមមាត្រានេះ ត្រូវគ្រប់គ្រងដោយច្បាប់នៃភាគីហត្ថលេខីដែលត្រូវបានអះអាងឱ្យការពារ[៥]។

## មាត្រា៦

## សិទ្ធិបេតិកភណ្ឌរបស់អ្នកសម្តែងចំពោះការសម្តែងដែលមិនបានថតបញ្ចូល

អ្នកសម្តែងត្រូវទទួលបានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតចំពោះការសម្តែងរបស់ខ្លួនៈ

(i) ការផ្សាយតាមទូរផ្សាយនិងការផ្សព្វផ្សាយជាសាធារណៈនៃការសម្តែង ដែលមិនទាន់បានថតបញ្ចូល លើកលែងតែការសម្តែងនេះជាការសម្តែងដែលបានផ្សាយតាមទូរផ្សាយរួចហើយ និង

(ii) ការថតបញ្ចូលនូវការសម្តែងរបស់ខ្លួនដែលមិនទាន់បានថតបញ្ចូល។

## មាត្រា៧

## សិទ្ធិផលិតឡើងវិញ

អ្នកសម្តែងត្រូវទទួលបានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាត ដោយផ្ទាល់ឬមិនផ្ទាល់ក្នុងការផលិតឡើងវិញនូវការសម្តែងរបស់ខ្លួន ដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្ស-ន៍ តាមរបៀបឬទម្រង់ណាមួយក៏ដោយ[៦]។

---

[៥] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា៥: ក្នុងគោលបំណងនៃសន្ធិសញ្ញានេះនិងមិនធ្វើឱ្យប៉ះពាល់ដល់សន្ធិសញ្ញាណាមួយផ្សេងទៀត ដោយពិចារណាដល់លក្ខណៈនៃការថតបញ្ចូលសោតទស្សន៍ ការផលិតនិងការចែកចាយ ត្រូវយល់ថា ការកែប្រែខ្លឹមសារនៃការសម្តែងដែលមានក្នុងពេលធ្វើអាជីវកម្មជាប្រក្រតីនៃការសម្តែង ដូចជាការបោះពុម្ពផ្សាយ ការបញ្ចូល ការបញ្ចូលសម្លេង ឬការរៀបចំអត្ថបទ ក្នុងសារព័ត៌មានឬការរៀបចំដែលមានស្រាប់ឬថ្មី និងដែលមានក្នុងពេលប្រើប្រាស់ដែលមានការអនុញ្ញាតពីអ្នកសម្តែង ការកែប្រែខ្លឹមសារនេះ នឹងមិនត្រូវជាការកែប្រែខ្លឹមសារតាមអត្ថន័យនៃមាត្រា៥(១)(ii)ឡើយ។ សិទ្ធិទាំងឡាយដែលមានក្នុងមាត្រា៥(១)(ii) តាមកម្មវត្ថុទាក់ទងតែនឹងការផ្លាស់ប្តូរដែលជាកម្មវត្ថុដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់កេរ្តិ៍ឈ្មោះអ្នកសម្តែង។ ក៏ត្រូវយល់ផងដែរថាត្រឹមតែការប្រើប្រាស់នូវបច្ចេកវិជ្ជា ឬសារព័ត៌មានថ្មី ឬមានការផ្លាស់ប្តូរ គឺមិនមែនជាការកែប្រែខ្លឹមសារតាមអត្ថន័យនៃមាត្រា៥(១)(ii)ឡើយ។

[៦] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា៧: ដូចមានចែងក្នុងមាត្រា៧ សិទ្ធិផលិតឡើងវិញនិង ការលើកលែងដែលអនុញ្ញាតតាមមាត្រា១៣ត្រូវអនុវត្តទាំងស្រុងក្នុងបរិបទឌីជីថល ជាពិសេសចំពោះការប្រើប្រាស់ការសម្តែ-ងក្នុងទម្រង់ឌីជីថល។ ត្រូវយល់ថាការរក្សាទុកការសម្តែងដែលបានការពារក្នុងទម្រង់ឌីជីថលតាមមធ្យោបាយអេឡិចត្រូ-និចណាមួយ ជាការផលិតឡើងវិញតាមអត្ថន័យនៃមាត្រានេះ។

## មាត្រា៨
## សិទ្ធិចែកចាយ

(១) អ្នកសម្តែងត្រូវទទួលបានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាត ឱ្យដាក់ផ្សាយជាសាធារណៈនូវការសម្តែងរបស់ខ្លួន ដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍ ច្បាប់ដើមនិងចម្លងតាមរយៈការលក់ឬការផ្ទេរសិទ្ធិផ្សេងទៀត។

(២) សន្ធិសញ្ញានេះមិនត្រូវចែងប៉ះពាល់ដល់សេរីភាពរបស់ភាគីហត្ថលេខី ក្នុងការកំណត់លក្ខខណ្ឌ ប្រសិនបើមាន ក្នុងការអនុវត្តការអស់សិទ្ធិនៃកថាខណ្ឌ(១) បន្ទាប់ពីការលក់លើកដំបូងឬការផ្ទេរសិទ្ធិនៃការសម្តែងដែលបានថតបញ្ចូល ជាច្បាប់ដើមឬចម្លងផ្សេងទៀតដោយមានការអនុញ្ញាតពីអ្នកសម្តែង[៧]។

## មាត្រា៩
## សិទ្ធិជួល

(១) អ្នកសម្តែងត្រូវទទួលបានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាត ចំពោះការជួលលក្ខណៈពាណិជ្ជកម្ម ជាសាធារណៈនូវការសម្តែងរបស់ខ្លួនដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍ ច្បាប់ដើមនិងចម្លងដូចមានចែងក្នុងច្បាប់ជាតិនៃភាគីហត្ថលេខី ទោះបីបន្ទាប់ពីមានការចែកចាយដោយអ្នកសម្តែងឬមានការអនុញ្ញាតពីអ្នកសម្តែងក៏ដោយ។

(២) ភាគីហត្ថលេខីអាចរួចផុតពីកាតព្វកិច្ចនៃកថាខណ្ឌ(១) លុះត្រាតែការជួលលក្ខណៈពាណិជ្ជកម្មនាំឱ្យរីកដុះដាលនូវការចម្លងនៃការថតបញ្ចូល ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិផ្តាច់មុខក្នុងការផលិតឡើងវិញរបស់អ្នកសម្តែង[៨]។

## មាត្រា១០
## សិទ្ធិដាក់ផ្សាយការសម្តែងដែលបានថតបញ្ចូល

អ្នកសម្តែងត្រូវទទួលបានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាត ឱ្យដាក់ផ្សាយជាសាធារណៈនូវការសម្តែងរបស់ខ្លួនដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍ តាមមធ្យោបាយមានខ្សែឬឥតខ្សែ តាមរបៀបដែលជនណាម្នាក់អាចទទួលបានស្នាដៃទាំងនេះពីកន្លែង និងពេលវេលាដែលជ្រើសរើសដោយជននេះ។

---

[៧] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា៨និង៩: ដូចដែលបានប្រើក្នុងមាត្រាទាំងនេះ ពាក្យ"ច្បាប់ដើមនិងចម្លង" ដែលជាកម្មវត្ថុនៃសិទ្ធិចែកចាយនិងសិទ្ធិជួលតាមមាត្រាខាងលើ ជាការយោងដោយឡែកដល់ច្បាប់ចម្លងដែលបានបញ្ចូលដែលអាចដាក់ឱ្យចរាចរជាវត្ថុរូបិយ។

[៨] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា៨និង៩: ដូចដែលបានប្រើក្នុងមាត្រាទាំងនេះ ពាក្យ"ច្បាប់ដើមនិងចម្លង" ដែលជាកម្មវត្ថុនៃសិទ្ធិចែកចាយនិងសិទ្ធិជួលតាមមាត្រាខាងលើ ជាការយោងដោយឡែកដល់ច្បាប់ចម្លងដែលបានបញ្ចូលដែលអាចដាក់ឱ្យចរាចរជាវត្ថុរូបិយ។

## មាត្រា១១
## សិទ្ធិផ្សាយតាមទូរផ្សាយនិងផ្សព្វផ្សាយជាសាធារណៈ

(១) អ្នកសម្ដែងត្រូវទទួលបានសិទ្ធិផ្ដាច់មុខក្នុងការអនុញ្ញាត ឱ្យផ្សាយតាមទូរផ្សាយនិងផ្សព្វផ្សាយជាសាធារណៈ នូវការសម្ដែងរបស់ខ្លួនដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍។

(២) ជំនួសឱ្យសិទ្ធិក្នុងការអនុញ្ញាតដែលមានចែងក្នុងកថាខណ្ឌ(១) ភាគីហត្ថលេខីអាចប្រកាសក្នុងសេចក្ដីជូនដំណឹង ដែលតម្កល់ជូនអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកថា ខ្លួននឹងបង្កើតសិទ្ធិទទួលបានលាភការសមរម្យចំពោះការប្រើប្រាស់ដោយផ្ទាល់ឬប្រយោល នៃការសម្ដែងដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍ ដើម្បីផ្សាយតាមទូរផ្សាយឬការផ្សព្វផ្សាយជាសាធារណៈ។ ភាគីហត្ថលេខីក៏អាចប្រកាសថា នឹងកំណត់លក្ខខណ្ឌក្នុងច្បាប់របស់ខ្លួនដើម្បីអនុវត្តសិទ្ធិទទួលបានលាភការសមរម្យ។

(៣) ភាគីហត្ថលេខីណាមួយ អាចប្រកាសថាខ្លួននឹងអនុវត្តបទប្បញ្ញត្តិនៃកថាខណ្ឌ(១) ឬ(២) តែចំពោះការប្រើប្រាស់មួយចំនួន ឬប្រកាសថាខ្លួននឹងកម្រិតការអនុវត្តបទប្បញ្ញត្តិទាំងនេះតាមរបៀបផ្សេងទៀត ឬប្រកាសថាខ្លួននឹងមិនអនុវត្តបទប្បញ្ញត្តិនៃកថាខណ្ឌ(១) និង(២)នេះតែម្ដង។

## មាត្រា១២
## ការផ្ទេរសិទ្ធិ

(១) ក្នុងច្បាប់ជាតិរបស់ខ្លួន នៅពេលដែលអ្នកសម្ដែងបានយល់ព្រមឱ្យមានការថតបញ្ចូលការសម្ដែងរបស់ខ្លួនក្នុងការថតបញ្ចូលសោតទស្សន៍ ភាគីហត្ថលេខីអាចចែងថា សិទ្ធិផ្ដាច់មុខក្នុងការអនុញ្ញាត ដែលមានចែងក្នុងមាត្រា៧ដល់មាត្រា១១នៃសន្ធិសញ្ញានេះ អាចត្រូវក្លាយជាកម្មសិទ្ធិឬអនុវត្តដោយ ឬផ្ទេរទៅឱ្យផលិតករនៃការថតបញ្ចូលសោតទស្សន៍នេះ លើកលែងតែមានកិច្ចសន្យាចែងផ្ទុយរវាងអ្នកសម្ដែងនិងផលិតករនៃការថតបញ្ចូលសោតទស្សន៍ ដូចដែលបានកំណត់ក្នុងច្បាប់ជាតិ។

(២) ចំពោះការថតបញ្ចូលសោតទស្សន៍ ដែលបានផលិតឡើងតាមច្បាប់ជាតិរបស់ខ្លួន ភាគីហត្ថលេខីអាចតម្រូវថា ការយល់ព្រមឬកិច្ចសន្យាខាងលើត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយភាគីទាំងពីរនៃកិច្ចសន្យា ឬដោយអ្នកតំណាងរបស់ភាគីដែលបានទទួលការអនុញ្ញាត្រឹមត្រូវ។

(៣) ដោយឯករាជ្យពីការផ្ទេរសិទ្ធិផ្ដាច់មុខដូចដែលបានរៀបរាប់ខាងលើ ច្បាប់ជាតិឬឯកត្តបុគ្គល សមូហភាព ឬកិច្ចព្រមព្រៀងផ្សេងទៀតអាចផ្ដល់ឱ្យអ្នកសម្ដែងនូវសិទ្ធិទទួល

បានលាភការឬកម្រៃសមរម្យ សម្រាប់ការប្រើប្រាស់ការសម្តែង ដូចមានចែងក្នុងសន្ធិសញ្ញានេះរួមមានមាត្រា១០និងមាត្រា១១។

## មាត្រា១៣

## ការកម្រិតនិងការលើកលែង

(១) ក្នុងច្បាប់ជាតិរបស់ខ្លួន ភាគីហត្ថលេខីអាចចែងការកម្រិតឬការលើកលែងដូចគ្នាចំពោះកិច្ចការពារអ្នកសម្តែង ដែលប្រទេសទាំងនេះបានចែងក្នុងច្បាប់ជាតិរបស់ខ្លួនទាក់ទងនឹងកិច្ចការពារសិទ្ធិអ្នកនិពន្ធនៃស្នាដៃអក្សរសាស្ត្រនិងសិល្បៈ ។

(២) ភាគីហត្ថលេខីត្រូវកំណត់ការកម្រិតឬការលើកលែងសិទ្ធិណាមួយ ដែលបានចែងក្នុងសន្ធិសញ្ញានេះចំពោះករណីពិសេសមួយចំនួន ដែលមិនធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មជាប្រក្រតីនៃការសម្តែង និងមិនធ្វើឱ្យខូចខាតដោយមិនសមហេតុផលទៅលើផលប្រយោជន៍ស្របច្បាប់របស់អ្នកសម្តែង[៩]។

## មាត្រា១៤

## រយៈពេលនៃកិច្ចការពារ

រយៈពេលនៃកិច្ចការពារដែលបានផ្តល់ឱ្យអ្នកសម្តែង តាមសន្ធិសញ្ញានេះ ត្រូវមានយ៉ាងហោចណាស់៥០(ហាសិប)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំដែលការសម្តែងបានថតបញ្ចូល។

## មាត្រា១៥

## កាតព្វកិច្ចចំពោះវិធានការបច្ចេកវិជ្ជា

ភាគីហត្ថលេខីត្រូវផ្តល់កិច្ចការពារស្របច្បាប់សមរម្យ និងវិធានការដោះស្រាយស្របច្បាប់ឱ្យមានប្រសិទ្ធិភាព ទល់នឹងការបង្វៀងវិធានបច្ចេកវិជ្ជាដែលមានប្រសិទ្ធិភាពហើយដែលត្រូវបានប្រើប្រាស់ដោយអ្នកសម្តែង ទាក់ទងនឹងការអនុវត្តសិទ្ធិរបស់ខ្លួនតាមសន្ធិ-សញ្ញានេះ និងដែលកម្រិតសកម្មភាពមួយចំនួនចំពោះការសម្តែងរបស់ខ្លួន ដែលអ្នក-សម្តែងមិនអនុញ្ញាតឬច្បាប់មិនអនុញ្ញាត[១០,១១]។

---

[៩] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា១៣: សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា១០(ស្តីពីការកម្រិតនិងការលើកលែង) នៃសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីសិទ្ធិអ្នកនិពន្ធ(WCT)ត្រូវអនុវត្តដូចគ្នាផងដែរចំពោះមាត្រា១៣(ស្តីពីការកម្រិតនិងការលើកលែង)នៃសន្ធិសញ្ញានេះ។

[១០] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា១៥ដែលទាក់ទងនឹងមាត្រា១៣: ត្រូវយល់ថាគ្មានមាត្រាណាមួយរារាំងភាគីហត្ថលេខីមិនឱ្យអនុម័តវិធានការចាំបាច់និងមានប្រសិទ្ធិភាពដើម្បីធានាថា អ្នកទទួលផលអាចទទួលការកម្រិតនិងការលើកលែងដែលមានចែងក្នុងច្បាប់ជាតិរបស់ភាគីហត្ថលេខីនេះ ស្របតាមមាត្រា១៣ នៅពេលដែលវិធានការបច្ចេកវិជ្ជាត្រូវបានអនុវត្តចំពោះការសម្តែងសោតទស្សន៍ ហើយអ្នកទទួលផលមានសិទ្ធិស្របច្បាប់ចំពោះការសម្តែងនេះ ក្នុងកាលៈទេសៈនានាដូចជានៅពេលដែលម្ចាស់សិទ្ធិមិនបានចាត់វិធានការសមរម្យនិងមានប្រសិទ្ធិភាពទាក់ទងនឹងការសម្តែងដើម្បីឱ្យអ្នកទទួលផលទទួលបានការកម្រិតនិងលើកលែងតាមច្បាប់ជាតិរបស់ភាគីហត្ថលេខី។

## មាត្រា១៦

## កាតព្វកិច្ចចំពោះសិទ្ធិគ្រប់គ្រងព័ត៌មាន

(១) ភាគីហត្ថលេខីត្រូវផ្តល់នូវវិធានការដោះស្រាយសមរម្យ និងមានប្រសិទ្ធិភាពស្របច្បាប់ទល់នឹងបុគ្គលណាដោយចេតនាដែលបានប្រព្រឹត្តនូវសកម្មភាពណាមួយ ដូចខាងក្រោមដោយបានដឹង ឬចំពោះសំណងរដ្ឋប្បវេណីមានមូលហេតុសមរម្យថាដឹង ថាអំពើនេះនឹងធ្វើឱ្យ ជម្រុញ ជួយសម្រួលឬលាក់បាំង ចំពោះការរំលោភសិទ្ធិណាមួយដែលមានចែងក្នុងសន្ធិសញ្ញានេះ :

(i) ដើម្បីដកចេញ ឬកែប្រែនូវព័ត៌មានស្តីពីការគ្រប់គ្រងសិទ្ធិតាមទម្រង់អេឡិចត្រូនិចណាមួយដោយគ្មានការអនុញ្ញាត

(ii) ដើម្បីចែកចាយ នាំចូលដើម្បីចែកចាយ ផ្សាយតាមទូរផ្សាយ ផ្សព្វផ្សាយឬដាក់ជូនជាសាធារណៈដោយគ្មានការអនុញ្ញាតនូវការសម្តែង ឬច្បាប់ចម្លងនៃការសម្តែងដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍ ដោយដឹងថាព័ត៌មានស្តីពីការគ្រប់គ្រងសិទ្ធិតាមទម្រង់អេឡិចត្រូនិចត្រូវបានគេលុបចោលឬកែប្រែរួចហើយ ដោយគ្មានការអនុញ្ញាត។

(២) ដូចមានចែងក្នុងមាត្រានេះ "សិទ្ធិគ្រប់គ្រងព័ត៌មាន" មានន័យថា ជាព័ត៌មានដែលផ្តល់អត្តសញ្ញាណចំពោះអ្នកសម្តែង ការសម្តែងរបស់អ្នកសម្តែង ឬម្ចាស់សិទ្ធិណាមួយនៃការសម្តែង ឬជាព័ត៌មានអំពីរយៈពេលនិងលក្ខខណ្ឌនៃការប្រើប្រាស់ការសម្តែង និងលេខ ឬលេខកូដដែលចែងឱ្យដឹងនូវព័ត៌មានទាំងនោះ នៅពេលដែលធាតុនៃព័ត៌មានទាំងនេះភ្ជាប់នឹងការសម្តែងដែលបានថតបញ្ចូលក្នុងការថតបញ្ចូលសោតទស្សន៍[១២]។

---

ដោយមិនប៉ះពាល់ដល់កិច្ចការពារស្របច្បាប់នៃស្នាដៃសោតទស្សន៍ ដែលមានការថតបញ្ចូលការសម្តែងត្រូវយល់បន្ថែមទៀតថាកាតព្វកិច្ចតាមមាត្រា១៥ មិនត្រូវបានអនុវត្តចំពោះការសម្តែងដែលមិនបានកិច្ចការពារឬលែងត្រូវបានការពារតាមច្បាប់ជាតិដែលផ្តល់អានុភាពចំពោះសន្ធិសញ្ញានេះ។

[១១] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា១៥: ពាក្យ"វិធានការបច្ចេកវិជ្ជាប្រើប្រាស់ដោយអ្នកសម្តែង" ដូចករណីដែលទាក់ទងនឹងសន្ធិសញ្ញាWPPT គួរបកស្រាយឱ្យទូលាយ ដោយយោងផងដែរដល់ជនណាដែលធ្វើក្នុងនាមអ្នកសម្តែងរាប់បញ្ចូលទាំងអ្នកតំណាង អ្នកទទួលអាជ្ញាប័ណ្ណឬអ្នកទទួលសិទ្ធិដូចជា ផលិតករ អ្នកផ្តល់សេវា និងបុគ្គលទាំងឡាយដែលបានចូលរួមក្នុងការផ្សព្វផ្សាយឬការផ្សាយតាមទូរផ្សាយ ដោយប្រើប្រាស់ការសម្តែងដែលមានការអនុញ្ញាតត្រឹមត្រូវ។

[១២] សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា១៦: សេចក្តីអះអាងដែលបានព្រមព្រៀងទាក់ទិននឹងមាត្រា១២(ស្តីពីកាតព្វកិច្ចចំពោះសិទ្ធិគ្រប់គ្រងព័ត៌មាន)នៃសន្ធិសញ្ញាWCT ត្រូវអនុវត្តដូចគ្នាផងដែរចំពោះមាត្រា១៦ (ស្តីពីកាតព្វកិច្ចចំពោះសិទ្ធិគ្រប់គ្រងព័ត៌មាន)នៃសន្ធិសញ្ញានេះ។

## មាត្រា១៧
## លក្ខខណ្ឌទម្រង់

ការទទួលបានសិទ្ធិនិងការអនុវត្តសិទ្ធិ ដែលបានកំណត់ក្នុងសន្ធិសញ្ញានេះមិនមែនជាកម្មវត្ថុនៃលក្ខខណ្ឌទម្រង់ណាមួយឡើយ។

## មាត្រា១៨
## ខរក្សាសិទ្ធិនិងសេចក្តីជូនដំណឹង

(១) លើកលែងតែបទប្បញ្ញត្តិនៃមាត្រា១១(៣) សន្ធិសញ្ញានេះមិនអនុញ្ញាតឱ្យមានខ-រក្សាសិទ្ធិទេ។

(២) សេចក្តីជូនដំណឹងណាមួយតាមមាត្រា១១(២)ឬ១៩(២) អាចត្រូវបានធ្វើក្នុងលិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬចូលជាសមាជិក ហើយកាលបរិច្ឆេទសុពលភាពនៃសេចក្តីជូនដំណឹងត្រូវដូចគ្នានឹងកាលបរិច្ឆេទនៃការចូលជាធរមាននៃសន្ធិសញ្ញានេះ ចំពោះភាគី-ហាត្ថលេខីដែលបានជូនដំណឹង។ សេចក្តីជូនដំណឹងនេះក៏អាចត្រូវបានធ្វើនាពេលបន្ទាប់ក៏បាន ហើយក្នុងករណីនេះសេចក្តីជូនដំណឹងត្រូវមានអានុភាព ៣(បី)ខែបន្ទាប់ពីអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកទទួលបានសេចក្តីជូនដំណឹងនេះ ឬតាមកាលបរិច្ឆេទក្រោយទៀតដែលបញ្ជាក់ក្នុងសេចក្តីជូនដំណឹង។

## មាត្រា១៩
## ការអនុវត្តក្នុងពេលវេលា

(១) ភាគីហត្ថលេខីត្រូវផ្តល់កិច្ចការពារដែលផ្តល់ឱ្យតាមសន្ធិសញ្ញានេះ ចំពោះការសម្តែងដែលបានថតបញ្ចូលដែលមាន ស្របពេលដែលការចូលជាធរមាននៃសន្ធិសញ្ញានេះ និងចំពោះការសម្តែងទាំងអស់ដែលបានបង្កើតឡើងបន្ទាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានេះសម្រាប់ភាគីហត្ថលេខីនីមួយៗ។

(២) ដោយមិនគិតដល់បទប្បញ្ញត្តិនៃកថាខណ្ឌ(១) ភាគីហត្ថលេខីអាចប្រកាសក្នុងសេ-ចក្តីជូនដំណឹង ដែលតម្កល់ជូនអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ថាខ្លួននឹងមិនអនុវត្តបទប្បញ្ញត្តិនៃមាត្រា៧ដល់មាត្រា១១នៃសន្ធិសញ្ញានេះឬ មាត្រាណាមួយក្នុងចំណោមមាត្រាទាំងនេះ ចំពោះការសម្តែងដែលបានថតបញ្ចូលដែលមានស្របពេលដែលការចូលជាធរមាននៃសន្ធិសញ្ញានេះសម្រាប់ភាគីហត្ថលេខីនីមួយៗ។ ចំពោះភាគីហត្ថលេខីនេះ ភាគីហត្ថលេខីផ្សេងទៀតអាចកម្រិតការអនុវត្តមាត្រាខាងលើចំពោះការសម្តែងដែលបានបង្កើតឡើងបន្ទាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានេះ សម្រាប់ភាគីហត្ថលេខីផ្សេងទៀតនេះ។

(៣) កិច្ចការពារដែលបានចែងក្នុងសន្ធិសញ្ញានេះ មិនត្រូវប៉ះពាល់ដល់សកម្មភាពណាមួយដែលបានប្រព្រឹត្តចំពោះកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ឬសិទ្ធិដែលទទួលបានមុនការចូលជាធរមាននៃសន្ធិសញ្ញានេះ សម្រាប់ភាគីហត្ថលេខីនីមួយៗ។

(៤) មុនការចូលជាធរមាននៃសន្ធិសញ្ញានេះ ក្នុងច្បាប់ជាតិរបស់ខ្លួន ភាគីហត្ថលេខីទាំងឡាយអាចបង្កើតអន្តរប្បញ្ញត្តិ ចំពោះបុគ្គលណាដែលបានធ្វើសកម្មភាពស្របច្បាប់ក្នុងការសម្តែង ចំពោះការសម្តែងដូចគ្នានេះអាចបំពេញសកម្មភាពនានាក្នុងក្របខណ្ឌនៃសិទ្ធិដែលមានចែងក្នុងមាត្រា៥និងមាត្រា៧ដល់មាត្រា១១បន្ទាប់ពីសន្ធិសញ្ញានេះចូលជាធរមានចំពោះភាគីហត្ថលេខីរៀងៗខ្លួន។

## មាត្រា២០

## បទប្បញ្ញត្តិចំពោះការអនុវត្តសិទ្ធិ

(១) អនុលោមតាមប្រព័ន្ធច្បាប់របស់ខ្លួន ភាគីហត្ថលេខីសន្យានឹងអនុម័តវិធានការ នា-នាដែលចាំបាច់ដើម្បីធានាការអនុវត្តសន្ធិសញ្ញានេះ។

(២) ភាគីហត្ថលេខីត្រូវធានាឱ្យមាននីតិវិធីអនុវត្តក្នុងច្បាប់របស់ខ្លួន ដើម្បីអនុញ្ញាតឱ្យមានបណ្តឹងទល់នឹងសកម្មភាពណាមួយនៃការរំលោភសិទ្ធិ ដែលមានចែងក្នុងសន្ធិសញ្ញានេះរួមទាំងវិធានការដោះស្រាយបន្ទាន់ដើម្បីរារាំងការរំលោភសិទ្ធិ និងវិធានការដោះស្រាយនានាដែលធ្វើឱ្យរាងចាលចំពោះការរំលោភសិទ្ធិក្រោយៗទៀត។

## មាត្រា២១

## សន្និបាត

(១) (ក) ភាគីហត្ថលេខីត្រូវមានសន្និបាតមួយ។

(ខ) ភាគីហត្ថលេខីនីមួយៗត្រូវតំណាងក្នុងសន្និបាតដោយប្រតិភូមួយរូប ដែលអាចអមដោយប្រតិភូស្តីទី ទីប្រឹក្សា និងអ្នកជំនាញការមួយចំនួន។

(គ) ការចំណាយរបស់គណៈប្រតិភូនីមួយៗជាបន្ទុករបស់ភាគីហត្ថលេខី ដែលតែងតាំងគណៈប្រតិភូនេះ។ សន្និបាតអាចស្នើរសុំទៅអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីផ្តល់ហិរញ្ញវត្ថុជួយសម្រួលការចូលរួមរបស់គណៈប្រតិភូនៃភាគីហត្ថលេខី ដែលត្រូវបានចាត់ទុកថាជាប្រទេសកំពុងអភិវឌ្ឍន៍ដោយអនុលោមតាម ការអនុវត្តពីមុនរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ ឬជាប្រទេសដែលឈានទៅរកសេដ្ឋកិច្ចទីផ្សារ។

(២) (ក) សន្និបាតត្រូវពិភាក្សារាល់បញ្ហាទាំងអស់ដែលទាក់ទងនឹង ការរក្សាការអភិវ-ឌ្ឍន៍សន្ធិសញ្ញានេះ ការអនុវត្តនិងការប្រព្រឹត្តទៅនៃសន្ធិសញ្ញានេះ។

(ខ) សន្និបាតត្រូវបំពេញការងារដែលមានចែងក្នុងមាត្រា២៣(២) ទាក់ទងនឹងការទទួលយកអង្គការអន្តររដ្ឋាភិបាលមួយចំនួនដើម្បីក្លាយជាភាគីនៃសន្ធិសញ្ញានេះ។

(គ) សន្និបាតត្រូវសម្រេចកោះប្រជុំសន្និសីទការទូតសម្រាប់ធ្វើការកែប្រែ សន្ធិសញ្ញានេះ និងផ្តល់ការណែនាំចាំបាច់ ជូនអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកដើម្បីរៀបចំសន្និសីទការទូតនេះ។

(៣)(ក) ភាគីហត្ថលេខីនីមួយៗដែលជារដ្ឋ មានសម្លេងឆ្នោតមួយ ហើយអាចបោះឆ្នោតក្នុងនាមខ្លួនតែប៉ុណ្ណោះ។

(ខ) ភាគីហត្ថលេខីដែលជាអង្គការអន្តររដ្ឋាភិបាលអាចចូលរួមបោះឆ្នោត ដើម្បីជំនួសរដ្ឋជាសមាជិករបស់ខ្លួនតាមចំនួនសម្លេងឆ្នោត ដែលស្មើនឹងចំនួនរដ្ឋជាសមាជិកដែលជាភាគីនៃសន្ធិសញ្ញានេះ។ អង្គការអន្តររដ្ឋាភិបាលនេះមិនត្រូវចូលរួមបោះឆ្នោតឡើយប្រសិនបើរដ្ឋសមាជិកណាមួយបានអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន។ ប្រសិនបើរដ្ឋជាសមាជិកណាមួយមិនបានអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន នោះអង្គការអន្តររដ្ឋាភិបាលនេះត្រូវចូលរួមបោះឆ្នោតបាន។

(៤) សន្និបាតត្រូវប្រជុំតាមការកោះប្រជុំ របស់អគ្គនាយកហើយបើគ្មានកាលៈទេសៈពិសេសត្រូវប្រជុំតាមពេលនិងទីកន្លែង ដូចនឹងមហាសន្និបាតរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។

(៥) សន្និបាតត្រូវព្យាយាមសម្រេចសេចក្តីជាឯកច្ឆ័ន្ទ និងត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន រួមទាំងការកោះប្រជុំវិសាមញ្ញ លក្ខខណ្ឌកូរ៉ុម ហើយលើកលែងតែបទប្បញ្ញត្តិសន្ធិសញ្ញានេះចែងផ្ទុយ សម្លេងភាគច្រើនដែលត្រូវការសម្រាប់សេចក្តីសម្រេចមួយចំនួន ។

## មាត្រា២២

## ការិយាល័យអន្តរជាតិ

ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ត្រូវបំពេញការងាររដ្ឋបាលទាក់ទងនឹងសន្ធិសញ្ញានេះ។

## មាត្រា២៣

## លក្ខខណ្ឌដើម្បីក្លាយជាភាគីនៃសន្ធិសញ្ញា

(១) រដ្ឋជាសមាជិកណាមួយរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក អាចក្លាយជាភាគីនៃសន្ធិសញ្ញានេះ។

(២) សន្និបាតអាចសម្រេចទទួលអង្គការអន្តររដ្ឋាភិបាលណាមួយ ដើម្បីក្លាយជាភាគីនៃសន្ធិសញ្ញានេះ ដែលបានប្រកាសថាខ្លួនមានសមត្ថកិច្ច ហើយមានច្បាប់ផ្ទាល់ខ្លួនដែលចងភ្ជាប់រដ្ឋជាសមាជិកទាំងអស់ ចំពោះបញ្ហាទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញានេះ

ហើយដែលបានប្រកាសថាខ្លួនត្រូវបានអនុញ្ញាតត្រឹមត្រូវតាមវិធានផ្ទៃក្នុងរបស់ខ្លួន ដើម្បីក្លាយជាភាគីនៃសន្ធិសញ្ញានេះ។

(៣) សហភាពអឺរ៉ុប ដែលបានធ្វើសេចក្តីប្រកាសតាមកថាខណ្ឌខាងលើក្នុងសន្និសីទការទូតដែលបានអនុម័តសន្ធិសញ្ញានេះអាចក្លាយជាភាគីនៃសន្ធិសញ្ញានេះបាន។

## មាត្រា២៤

## សិទ្ធិនិងកាតព្វកិច្ចតាមសន្ធិសញ្ញា

លើកលែងតែបទប្បញ្ញត្តិជាក់លាក់ណាមួយដែលផ្ទុយនឹងសន្ធិសញ្ញានេះ ភាគីហត្ថលេខីនីមួយៗត្រូវទទួលបានសិទ្ធិទាំងអស់ ហើយត្រូវសន្មត់ថាទទួលយករាល់កាតព្វកិច្ចទាំងអស់ក្នុងសន្ធិសញ្ញានេះផងដែរ។

## មាត្រា២៥

## ការចុះហត្ថលេខាលើសន្ធិសញ្ញា

សន្ធិសញ្ញានេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខា នៅទីស្នាក់ការអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដោយភាគីណាមួយដែលបំពេញគ្រប់លក្ខខណ្ឌក្នុងរយៈពេល១(មួយ)ឆ្នាំបន្ទាប់ពីការទទួលយកសន្ធិសញ្ញា។

## មាត្រា២៦

## ការចូលជាធរមាននៃសន្ធិសញ្ញ

សន្ធិសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល៣(បី)ខែ បន្ទាប់ពីមានការតម្កល់លិខិតតុបករណ៍នៃ ការផ្តល់សច្ចាប័នឬការចូលជាសមាជិក របស់ភាគីដែលបំពេញគ្រប់លក្ខខណ្ឌចំនួន៣០(សាមសិប) ដូចមានចែងក្នុងមាត្រា២៣ ។

## មាត្រា២៧

## កាលបរិច្ឆេទសុពលភាពដើម្បីក្លាយជាភាគីនៃសន្ធិសញ្ញា

សន្ធិសញ្ញានេះត្រូវចងភ្ជាប់:

(i) ភាគីដែលបំពេញគ្រប់លក្ខខណ្ឌចំនួន៣០(សាមសិប) ដូចមានចែងក្នុងមាត្រា២៦ គិតចាប់ពីកាលបរិច្ឆេទដែលសន្ធិសញ្ញានេះចូលជាធរមាន។

(ii) ភាគីដែលបំពេញគ្រប់លក្ខខណ្ឌផ្សេងទៀតដូចមានចែងក្នុងមាត្រា២៣ គិតចាប់ពីការផុតរយៈពេល៣(បី)ខែ ដោយរាប់ពីកាលបរិច្ឆេទដែលភាគីនោះបានតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិករបស់ខ្លួន ជូនអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

## មាត្រា២៨

## ការប្រកាសដកខ្លួនចេញពីសន្ធិសញ្ញា

ភាគីហត្ថលេខីអាចប្រកាសដកខ្លួនចេញពីសន្ធិសញ្ញានេះ តាមការជូនដំណឹងទៅអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ ការប្រកាសដកខ្លួនចេញណាមួយត្រូវមានអានុភាពអនុវត្ត ក្នុងរយៈពេល១ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកបានទទួលសេចក្តីជូនដំណឹងនេះ។

## មាត្រា២៩

## ភាសាក្នុងសន្ធិសញ្ញា

(១)សន្ធិសញ្ញានេះត្រូវបានចុះហត្ថលេខា លើច្បាប់ដើមតែមួយគត់ជាភាសា អង់គ្លេស ភាសាអារ៉ាប់ ភាសាចិន ភាសាបារាំង ភាសារុស្ស៊ី និងភាសាអេស្ប៉ាញ។ អត្ថបទនៃភាសាទាំងនេះមានតម្លៃស្មើៗគ្នា។

(២) អត្ថបទផ្លូវការជាភាសាណាមួយ ក្រៅពីភាសាដែលមានចែងក្នុងកថាខណ្ឌ(១)ត្រូវបង្កើតឡើងដោយអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក តាមការស្នើសុំរបស់ភាគីដែលពាក់ព័ន្ធនិងបន្ទាប់ពីកិច្ចពិភាក្សាយោបល់ជាមួយភាគីទាំងនោះ។ ក្នុងគោលបំណងនៃកថាខណ្ឌនេះ"ភាគីដែលពាក់ព័ន្ធ"មានន័យថា រដ្ឋជាសមាជិកណាមួយរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកដែលមានភាសាផ្លូវការ ឬភាសាមួយក្នុងចំណោមភាសាផ្លូវការ ហើយសហភាពអឺរ៉ុបនិងអង្គការអន្តររដ្ឋាភិបាលណាមួយផ្សេងទៀត ដែលអាចក្លាយជាភាគីនៃសន្ធិសញ្ញានេះប្រសិនបើមានភាសាផ្លូវការណាមួយក្នុងចំណោមភាសាទាំងឡាយ។

## មាត្រា៣០

## កន្លែងតម្កល់

អគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ជាកន្លែងតម្កល់សន្ធិសញ្ញានេះ។